# ការសំភាសន៍របស់ សំ សុវណ្ណា

កៈ អ្នកដែរសំភាសន៍ ជាង ស៊ីអាវ ខៈ អ្នកដែរអោយគេសំភាសន៍ សំ សុវណ្ណា

កៈ ចឹងជាដំបូងខ្ញុំអរគុណអ៊ុំដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់អ៊ុំហាស បាទចឹងដោយសារតែការសំភាសន៍នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថា BYU ហើយដាយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរទុកអោយកូនចៅជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិដូនតានឹងឪពុកម្តាយចឹងហាសអ៊ុំ ហើយនៅពេលដែរខ្ញុំបានសំភាសន៍អ៊ុំហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនឹងទៅក្នុងវេបសាយរបស់សាលា ហើយវេបសាយរបស់សាលាមានឈ្មោះថា www.cambodianoralhistories.byu.edu ហាសអ៊ុំបាទចឹងសំរាប់អ៊ុំតើអ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍មួយនឹងទៅក្នុងវេបសាយរបស់សាលាដែរទេអ៊ុំ?

ខៈ មានចីគ្រាន់តែសំភាសន៍ហោសលោកគ្រូ

កៈ បាទអ៊ុំចឹងសំរាប់ បាទអ៊ុំ?

ខៈ ប៉ុន្តែខុសត្រូវអីកុំប្រកាន់អីណា

កៈ អូអត់អីទេអ៊ុំការនិយាយរបស់សុទ្ធតែត្រូវទាំងអស់ ប៉ុន្តែដោយសារតែពេលខ្លះអ៊ុំមានការភ្លេចអីចឹងហាសអ៊ុំ ចឹងសំរាប់ខ្ញុំដែរជាអ្នកសំភាសន៍អ៊ុំខ្ញុំមានឈ្មោះថា ជាង ស៊ីអាវ

ខៈ ឈ្មោះជាង ស៊ីអ៊ាវ

កៈ បាទអ៊ុំហើយខ្ញុំសំភាសន៍នៅថ្ងៃទី 22 ខែ1 ឆ្នាំ2018 ហើយការសំភាសន៍ត្រូវបានធ្វើឡើងនៅភូមិ4 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន រាជធានីភ្នំពេញហាសអ៊ុំ បាទចឹងសំរាប់អ៊ុំឈ្មោះពេញរបស់អ៊ុំមានឈ្មោះអីគេដែរអ៊ុំ?

ខៈ ខ្ញុំមានឈ្មោះ សំ សុវណ្ណា

កៈ ឈ្មោះ សំ សុវណ្ណា ចុះមានឈ្មោះហៅក្រៅទេអ៊ុំ?

ខ៖ ឈ្មោះហៅក្រៅឈ្មោះ ស៊ា

ក៖ ឈ្មោះ ស៊ា ចុះកាលពីតូចមានគេហៅឈ្មោះអីគេផ្សេងទៀតទេអ៊ុំ?

ខ៖ មានតែប៉ុណ្ណឹង

ក៖ ចុះកាលពីនៅតូចក៏គេហៅស៊ាដែរ ចុះឥឡូវអ៊ុំអាយុប៉ុន្មានដែរអ៊ុំ?

ខ៖ ខ្ញុំអាយុ55ឆ្នាំ

ក៖ អូអ៊ុំអាយុ55ឆ្នាំ ចុះអ៊ុំមានដឹងថាអ៊ុំកើតនៅថ្ងៃ ខែ ឆ្នាំណាទេអ៊ុំ?

ខ៖ ខ្ញុំដឹងតែខ្ញុំកើតនៅ ទេខ្ញុំមិនដឹងទេនេះលោកគ្រូ

ក៖ ចុះ ថ្ងៃទី វិញ?

ខ៖ បើថ្ងៃ ថ្ងៃអង្គារ៍

ក៖ ថ្ងៃអង្គារ៍ ចុះទីប៉ុន្មានដែរអ៊ុំចាំទេ?

ខ៖ ទី19ទេហាស ទី19

ក៖ ទី19 ចុះខែអ៊ុំមានដឹងថាខែអីគេទេអ៊ុំ?

ខ៖ ខែមិនដឹងថាខែអីគេទេលោកគ្រូ ម៉ែគាត់ស្លាប់ចោលទៅចឹងអត់ដឹងហាស

ក៖ ចុះឆ្នាំវិញ?

ខ៖ បើឆ្នាំគឺឆ្នាំ1963

ក៖ ឆ្នាំ1963 ចុះសំរាសប់ឆ្នាំខ្មែរអ៊ុំមានដឹងថាអ៊ុំឆ្នាំអីគេទេអ៊ុំ ឆ្នាំច័ន្ទគតិហាស?

ខ៖ ខ្ញុំឆ្នាំខាល

ក៖ ឆ្នាំខាល ណាអ៊ុំ ចុះអ៊ុំកើតនៅណាដែរអ៊ុំ ទីកន្លែងកំណើតហាសអ៊ុំ?

ខ៖ កើតនៅភូមិចំបក ឃុំគ្រួស ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង

ក៖ ចុះសព្វថ្ងៃអ៊ុំមានបងប្អូនប៉ុន្មាននាក់ដែរអ៊ុំ?

ខ៖ ខ្ញុំមានបងប្អូនចំនួន5នាក់

កៈ ចុះមានស្រីប៉ុន្មាននាក់ ហើយមានប្រុសប៉ុន្មាននាក់ដែរអ៊ុំ?

ខៈ ខ្ញុំមានស្រីទាំងអស់ អត់មានប្រុសទេ

កៈ អូសុទ្ធតែស្រីអត់មានប្រុសទេហោសអ៊ុំ ចុះអ៊ុំជាកូនទីប៉ុន្មានដែរអ៊ុំ?

ខៈ ខ្ញុំជាកូនទី4

កៈ អ៊ុំជាកូនទី4ណាអ៊ុំ ចុះមានចងចាំសាច់រឿងអី
រឺមួយក៏អនុស្សាវរីយ៍ជាមួយគ្នាកាលពីនៅតូចធ្លាប់បានលេងងីជាមួយគ្នាដែរចឹងហាសអ៊ុំ?

ខៈ ខ្ញុំអត់មានលេងអីទេលោកគ្រូ

កៈ ចុះអ៊ុំមានធ្លាប់លេងបិទពួន រឺមួយក៏លេងគុបឈូសអីមានទេអ៊ុំ?

ខៈ អត់មានទេអានឹងមានលេងផងអានឹង

កៈ ចុះប៉ុន្មានធ្លាប់ទៅស្រែអីជាមួយបងប្អូនរបស់អ៊ុំដែរទេ?

ខៈ មានតែរាំច្រៀង

កៈ អូធ្លាប់លេងរាំងច្រៀងជាមួយគ្នាណាអ៊ុំ?

ខៈ ជាមួយក្រុមកងចល័ត

កៈ ប៉ុន្តែកាលពីនៅតូចៗហាសអ៊ុំមានធ្លាប់លេងអីជាមួយប្អូន
ដោយសារតែអ៊ុំអាយុ63ឆ្នាំចឹងបងប្អូនរបស់អ៊ុំនៅតូចៗដែរណាអ៊ុំ?

ខៈ នៅតូចខ្ញុំបន្ទាប់ពី៧

កៈ អូបន្ទាប់ពី៧ហោសអ៊ុំចុះអ៊ុំមានធ្លាប់ធ្វើអីជាមួយពួកគាត់ទេអ៊ុំ?

ខៈ អត់មានទេលោកគ្រូ

កៈ អត់ទេណាអ៊ុំ ចុះអ៊ុំអាចរៀបរាប់ឈ្មោះបងប្អូនរបស់អ៊ុំបានទេអ៊ុំ
បងធំមានឈ្មោះអីគេដែរអ៊ុំ?

ខៈ បងធំមានឈ្មោះសំ វណ្ណសាក់

កៈ អូឈ្មោះ សំ វណ្ណសាក់ ចុះបងទី2ហោសអ៊ុំ?

ខ៖ ឈ្មោះ សំវណ្ណ ស៊ាន អូច្រឡំ ឈ្មោះ សំវណ្ណ សួន ជាបងទី1

ក៖ ចុះបងទី2វិញ?

ខ៖ ទី2ឈ្មោះ សំវណ្ណ សាក់

ក៖ ចុះទី3វិញអ៊ុំ?

ខ៖ ទី3ឈ្មោះ សំវណ្ណ ស៊ាន

ក៖ ឈ្មោះ សំវណ្ណ ស៊ាន ទី4អ៊ុំ ឈ្មោះ សំ វណ្ណា ចុះទី5វិញ?

ខ៖ ទី5ឈ្មោះ សំគឹម សាន

ក៖ ទី5ឈ្មោះ សំគឹម សាន ចុះកាលពីនៅក្មេងអ៊ុំចូលចិត្តធ្វើអីគេជាមួយពួកគាត់ដែរអ៊ុំ?

ខ៖ ពួកខ្ញុំចូលចិត្តតែលេងរាំងច្រៀងនឹងថា

ក៖ រាំច្រៀង ចុះធ្លាប់ទៅស្រែជាមួយគ្នាអត់អ៊ុំ?

ខ៖ ទៅស្រែធ្វើស្រែ

ក៖ ទៅស្រែធ្វើស្រែ ចុះទៅដកស្ទូង រឺមួយក៏ទៅលេងទឹកអីធ្លាប៊ទេអ៊ុំ?

ខ៖ មាននៅដកស្ទូងកាលណុងនៅដកស្ទូងនឹងលោកគ្រូ

ក៖ ចុះមានធ្លាប់ទៅលេងទឹកអីជាមួយគ្នាទេអ៊ុំ?

ខ៖ លេងតែលេង រុះខាងនង្គ័លអស់ ឈប់លេងទៅ

ក៖ ចុះកាលនៅផ្ទះធ្លាប់លេងអីជាមួយពួកគាត់កាលពីនៅជាមួយឪពុកម្ដាយហាសអ៊ុំ ដូចជាចូលចិត្តលេងអី លក្ខណៈថា លេងបិទពួន រឺក៏លេងលក្ខណៈថាលេងអីមួយអោយសប្បាយដូចជាលេង បាយខំអីចឹងហាសអ៊ុំ?

ខ៖ លេងបាយខំ លេងបិទពួន នៅក្នុងវូង នៅក្នុងភូមិចំបកទាំងអស់នឹងក្មេងៗហាស

ក៖ ទាំងបងប្អូនទាំងអីចឹងទៅ?

ខ៖ ចាទាំងបងប្អូន ទាំងញ្ញាតិជិតខាងអីចឹងហាស

ក. លេងសាញ៉ េលេងអីចឹងហោស ណាអ៊ុំលេងរត់ពួនពេលយប់ៗឡើងអីចឹងហាស?

ខ៖ លេងទឹក លេងទោងតាអីនឹង

ក៖ ចុះបងប្អូនរបស់អ៊ុំសព្វថ្ងៃនឹងគាត់រស់នៅណាដែរអ៊ុំ?

ខ៖ រស់នៅភូមិចំបក ឃុំគ្រួស ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀងនឹង

ក៖ ទាំងអស់គ្នាតែម្តងហោសអ៊ុំ ?

ខ៖ ចានៅជុំគ្នានឹង

ក៖ ទាំងបងទី1 ទី2 នឹងបងទី3 នឹងមែន?

ខ៖ ចាទាំងអស់នឹងនៅជុំគ្នា

ក៖ ប៉ុន្តែផ្ទះរបស់ពួកគាត់នៅជុំគ្នាតែម្តង?

ខ៖ នៅជិតៗគ្នាទាំងអស់នឹងនៅម្តុំរិលជុំ

ក៖ អូសុម្បីតែអ៊ុំក៏នៅជិតណុងដែរហោសអ៊ុំ?

ខ៖ ចានឹងហើយនៅទាំងអស់គ្នាតែម្តងនឹង

ក៖ ចុះបងធំរបស់អ៊ុំគាត់ធ្វើអីគេដែរអ៊ុំ?

ខ៖ គាត់គ្មានធ្វើអីទេគាត់នៅចាំផ្ទះ

ក៖ អូគាត់នៅចាំផ្ទះហោសអ៊ុំ?

ខ៖ ចាកូនៗមកភ្នំពេញអស់ទៅ

ក៖ កូនមកធ្វើការងារនៅភ្នំពេញ គាត់នៅមើលចៅនៅផ្ទះចឹងទៅ
ចុះកាលពីមុនគាត់ធ្វើអីគេដែរអ៊ុំបងធំរបស់អ៊ុំ?

ខ៖ បងធំគាត់ខាងចុងភៅ

ក៖ អូគាត់ធ្វើចុងភៅហោស ចុះគាត់មានធ្លាប់ធ្វើស្រែអីទេ?

ខ៖ គាត់ទៅធ្វើស្រែ ចុងភៅអីនឹងមួយចប់នឹងគាត់

កៈ អូចុះបងទី2គាត់ធ្វើអីគេដែរអ៊ុំ?

ខៈ បងទី2គាត់មានធ្វើអីទេ តាគាត់អាចារ្យ

កៈ អូគាត់អាចារ្យហោស?

ខៈ ចាតារបស់គាត់អាចារ្យ គាត់គ្មានធ្វើអីទេ

កៈ ប៉ុន្តែគាត់ធ្លាប់ទៅធ្វើស្រែអីជាមួយអ៊ុំទេ?

ខៈ គាត់ទៅធ្វើស្រែ និយាយរួមគាត់ទៅធ្វើស្រែទាំងអស់នឹង

កៈ ចុះបងទី3គាត់ធ្វើអីគេដែរអ៊ុំ?

ខៈ បងទី3គាត់នៅមើលចៅ

កៈ គាត់នៅមើលចៅដែរហោសអ៊ុំតែគាត់អត់មានធ្វើអីដែរទេ?

ខៈ អត់មានធ្វើអីទេ មើលចៅទាំងអស់កូនរបស់គាត់ទៅធ្វើការ

កៈ បាទចុះអ៊ុំមើលចៅដែរ?

ខៈ ខ្ញុំមើលចៅនេះ

កៈ ប៉ុន្តែអ៊ុំនឹងទៅវិញដែរ?

ខៈ ខ្ញុំទៅតាទៅវិញ

កៈ ហើយក៏នាំចៅទៅដែរ?

ខៈ អត់ផងខ្ញុំនៅមួយខែទៅពីរខែ

កៈ អូបាទចុះប្អូនពៅរបស់អ៊ុំគាត់ធ្វើអីគេដែរអ៊ុំ?

ខៈ ប្អូនពៅរបស់ខ្ញុំនៅផ្ទះដែរ

កៈ អត់មានធ្វើអីទេ?

ខៈ នៅមើលចៅដែរ

កៈ អូនិយាយរួមបងប្អូនរបស់អ៊ុំសុទ្ធតែមានចៅអស់ហើយណាអ៊ុំ?

ខ៖ មានចៅអស់ហើយ

ក៖ ចុះម្ដាយរបស់អ៊ុំគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖ គាត់បានស្លាប់បាត់អស់ហើយ?

ក៖ ប៉ុន្តែគាត់មានឈ្មោះអីគេដែរអ៊ុំឈ្មោះពេញរបស់គាត់ហាស?

ខ៖ គាត់ឈ្មោះ សំ ពេញ

ក៖ ឈ្មោះសំ ពេញ ចុះគាត់មានអាយុប៉ុន្មានដែរអ៊ុំចងចាំទេ?
ខ៖ គាត់អាយុកាលគាត់ស្លាប់នឹងអាយុ67ឆ្នាំ

ក៖ ចុះគាត់អាយុ67ឆ្នាំ ចុះគាត់ស្លាប់ប៉ុន្មានឆ្នាំហើយអ៊ុំ?

ខ៖ យូរហើយលោកគ្រូ

ក៖ អ៊ុំគិតថាប្រហែលជាប៉ុន្មានឆ្នាំដែរអ៊ុំ?

ខ៖ ប្រហែលជា10ឆ្នាំជាងហើយមើលទៅ

ក៖ ប្រហែលជា10ឆ្នាំជាងណាអ៊ុំ ចឹងគាត់ស្លាប់ប្រហែលជាង10ឆ្នាំ
ចឹងគាត់កើតប្រហែលជាឆ្នាំ1941ណាអ៊ុំ ចុះអ៊ុំមានដឹងថ្ងៃ ខែគាត់អត់អ៊ុំ?

ខ៖ អត់ដឹងទេលោកគ្រូ

ក៖ ឆ្នាំខ្ទង់ប្រហែលជាឆ្នាំ1940ជាង គាត់ប្រហែលជាសែស្ដើង ដោយសារតែគាត់67ឆ្នាំ?

ខ៖ គាត់ស្លាប់នឹង67ឆ្នាំ ហាស ច្រឡំគាត់ស្លាប់នឹងអាយុ77ឆ្នាំ យូរហើយលោកគ្រូ
គាត់ស្លាប់បាត់យូរដែរហើយនឹង

ក៖ ចឹងប្រហែលជាគាត់កើតនៅខ្ទង់សាមសិបជាមែនទេអ៊ុំ

ក៖ នឹងម្ដាយមែនទេអ៊ុំ?

ខ៖ ចានឹងម្ដាយ

ក៖ ចុះគាត់កើតនៅណាដែរអ៊ុំ?

ខ៖ កើតនៅភូមិចំបក ឃុំគ្រួស ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង

កៈ អូគាត់កើតនៅណុងទាំងអស់គ្នាហោសអ៊ុំ ចុះឪពុករបស់អ៊ុំគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខៈ ឪពុករបស់ខ្ញុំឈ្មោះ ភឿក ចាន់

កៈ គាត់ឈ្មោះ ភឿក ចាន់ ចុះគាត់អាយុប៉ុន្មានដែរអ៊ុំ?

ខៈ គាត់អាយុកាលពីមិនទាន់ស្លាប់អាយុ87ឆ្នាំ

កៈ គាត់អាយុ87ឆ្នាំ ចុះគាត់ស្លាប់ប៉ុន្មានឆ្នាំដែរអ៊ុំ?

ខៈ គាត់ស្លាប់បាត់យូរដែរហើយលោកគ្រូ គាត់ចាស់រហូតដល់គាំចាស់ជរាហាសលោកគ្រូ

កៈ ចុះគាត់ស្លាប់ដល់10-20ឆ្នាំអត់អ៊ុំ?

ខៈ គាត់ស្លាប់ចង់ចូល20ឆ្នាំជាងហើយលោកគ្រូ

កៈ អូគាត់ស្លាប់ជាង20ឆ្នាំ ចឹងមានន័យថាឥឡូវមានតែគាត់អាយុ97ឆ្នាំណាអ៊ុំ?

ខៈ នឹងហើយប្រហែលជាប៉ុណ្ណឹង

កៈ បើគាត់អាយុ97ឆ្នាំ ចឹងគាត់កើតនៅឆ្នាំ1921 គាត់ចូលខ្ទង់20ឆ្នាំជាង?

ខៈ ចាត្រូវហើយ

កៈ ចុះអ៊ុំមានដឹងថាគាត់កើតនៅឆ្នាំអីទេអ៊ុំ ឪពុករបស់អ៊ុំគាត់ឆ្នាំជូត ឆ្លូវ ខាល ថោះគាត់ឆ្នាំអីគេអ៊ុំមានដឹងទេអ៊ុំ?

ខៈ គាត់ឆ្នាំអីទេលោកគ្រូវាភ្លេច ពីមុនដឹងតែដល់ពេលយូរៗទៅវាភ្លេចហាស

កៈ ចុះម្ដាយរបស់អ៊ុំគាត់ឆ្នាំអីគេអ៊ុំមានដឹងទេ រឺក៏អ៊ុំភ្លេចដែរ?

ខៈ នឹងហើយភ្លេចគាត់សុទ្ធចាស់ជរាហាសលោកគ្រូ

កៈ ចុះឪពុករបស់អ៊ុំគាត់កើតនៅណាដែរអ៊ុំ?

ខៈ ឪពុកគាត់កើតនៅ ភូមិចំបក ឃុំគ្រួស ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀងនឹងលោកគ្រូ

កៈ ចឹងមានន័យថាគាត់នៅភូមិជាមួយគ្នាហោសអ៊ុំ?

ខៈ ចានៅភូមិជាមួយគ្នានឹង

កៈ ចុះកាលពីឪពុករបស់អ៊ុំគាត់នៅរស់គាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខៈ គាត់មានការងារធ្វើស្រែច្រើនណាស់លោកគ្រូ

កៈ គាត់ធ្វើតែស្រែទេ គាត់អត់មានរកស៊ីលក់ដូរ ចិញ្ចឹមមាន់ ចិញ្ចឹមទា ចិញ្ចឹមជ្រូក ចិញ្ចឹមគោអីទេណាអ៊ុំ?

ខៈ ដូចថាកាលពីដើមគាត់មករត់ស៊ីក្លូអីនៅភ្នំពេញចឹងហាស

កៈ ចុះគាត់មានធ្លាប់ចិញ្ចឹមគោអីទេអ៊ុំ?

ខៈ អូនិយាយរឿងគោ ក្របីនឹងមិនខ្វះទេ

កៈ ច្រើនណាអ៊ុំ ចុះឪពុករបស់អ៊ុំជាមនុស្សបែបណាដែរអ៊ុំ គាត់ជាមនុស្សស្លូតរឺមួយក៏កាចដែរចឹងហាសអ៊ុំ?

ខៈ អូស្លូតណាស់ឪពុកម្តាយរបស់ខ្ញុំ

កៈ គាត់ស្លូតណ ចុះម្តាយរបស់អ៊ុំគាត់ស្លូតដែរ?

ខៈ ស្លូតគាត់ស្លូតណាស់

កៈ ចុះគាត់រកស៊ីអីគេដែរកាលពីគាត់នៅរស់ម្តាយរបស់អ៊ុំហាស?

ខៈ ម្តាយរបស់ខ្ញុំធ្វើស្រែ ចិញ្ចឹមគោ ចិញ្ចឹមជ្រូកអីនឹង

កៈ ចុះអ៊ុំមានចងចាំសាច់រឿងអីគេខ្លះដែរកាលពីអ៊ុំនៅជាមួយពួកគាត់ហាសអ៊ុំ កាលពីគាត់នៅរស់ហាសអ៊ុំ?

ខៈ ចាំប្រវត្តិថាគាត់មិនដែរវៃ មិនដែរជេពួកខ្ញុំទេតែប៉ុណ្ណឹង

កៈ ចុះពួកគាត់ធ្លាប់មាននាំអ៊ុំទៅស្រែទៅដើរលេងអីទេ?

ខៈ ទៅទៅៗកូនជាអ្នកទូលទឹក ម៉ែទូលបាយអីចឹងទៅ

កៈ ចុះមានចងចាំអនុស្សាវរីយ៍អីដែរអ៊ុំគិតថាអ៊ុំញាំុបាយ ដែរអ៊ុំគិតថាអ៊ុំមិនអាចភ្លេចហាសអ៊ុំមានចងចាំទេអ៊ុំ?

ខៈ ចាចឹមិនចាំ

កៈ ចុះអ៊ុំធ្វើអីគេដែរជាមួយគាត់?

ខៈ
ខ្ញុំគ្មានធ្វើអីទេពេលដែរគាត់ហើយពីស្នូងនឹងគាត់ហៅកូនៗមកហូបបាយនៅលើភ្លឺស្រែចឹងទៅ

កៈ ចុះអ៊ុំមានចងចាំទេថាអ៊ុំមានធ្វើអីគេមួយនៅផ្ទះដែរអ៊ុំគិតថាអ៊ុំចាំហាស ចាំដល់ឥឡូវចឹងហាសអ៊ុំមានទេ?

ខៈ ភ្លេចអស់ហើយលោកគ្រូច្រើនវគ្គ មកជំនាន់ពលពតចឹងពួកខ្ញុំមិនមកនៅផ្ទះផងនឹង

កៈ ប៉ុន្តែកាលពីជំនាន់ពលពតអ៊ុំមាននៅជាមួយពួកគាត់រឺអត់ទេអ៊ុំ?

ខៈ នៅជាមួយ

កៈ នៅជាមួយហោស ចុះពេលណុងគេអោយអ៊ុំធ្វើអីគេជាមួយពួកគាត់ដែរទៅអ៊ុំ?

ខៈ ខ្ញុំគេអោយទៅធ្វើកងចល័ត

កៈ អូធ្វើកងចល័តហោសអ៊ុំ ចុះពួកគាត់វិញអ៊ុំ?

ខៈ ឪពុករបស់ខ្ញុំគាត់មើលខាងមើលគោ មើលក្របីអីចឹងហាស

កៈ មើលនៅស្រុកណុង
ប៉ុន្តែកាលពីអ៊ុំនៅធ្វើជាកងចល័តនឹងតើអ៊ុំនៅជិតគាត់ដែររឺមួយន៍ឆ្ងាយដែរអ៊ុំ?

ខៈ មិននៅជិតទេនៅឆ្ងាយដែរលោកគ្រូ ដូចថាចង់ទៅ គេបញ្ជូនទៅឆ្ងាយក៏ឆ្ងាយទៅ គេបញ្ជូនមកជិត ក៏នៅជិតចឹងទៅ

កៈ ប៉ុន្តែនៅភូមិជាមួយគ្នាទៅ រឺមួយយ៉ាងម៉េចដែរអ៊ុំ?

ខៈ មិននៅជាមួយគ្នាទេ ដូចថាលោកគ្រូ ដូចតំរូវយើងត្រូវការចឹងហាស ទៅរោងចក្រចឹងទៅ ចំណែកម៉ែឪនៅភូមិនៅផ្ទះអីចឹងហាស ប្រៀបដូចចឹងហាស រួចទៅទៅលើកប្រពន្ធភ្លឺស្រែ លើកព្រែកលើកអីទៅកាលពីជំនាន់ណុងចឹងហាស សុទ្ធចប ចង្កឹរែកហាស

កៈ កាលពីអ៊ុំទៅនឹងតើអ៊ុំទៅតែម្នាក់អែងរឺមួយក៏ទៅជាមួយបងប្អូនដែរអ៊ុំ?

ខ៖ គ្មានទេបែកគ្នាទាំងអស់នឹង

ក៖ គេអោយទៅធ្វើកងចល័តផ្សេងៗគ្នាទាំងអស់?

ខ៖ ចាបែកគ្នា

ក៖ ប៉ុន្តែឪពុកម្តាយរបស់អ៊ុំគាត់បាននៅផ្ទះ?

ខ៖ គាត់នៅផ្ទះ

ក៖ អូចុះប៉ុន្មានខែបានយើងបានមកលេងផ្ទះបានម្តងចឹងហាសអ៊ុំ?

ខ៖ សុំ 10ថ្ងៃអីនឹងសុំមកបានតែមួយភ្លែតក៏ទៅវិញចឹងទៅ

ក៖ អូនឹងយើងមកលេងគ្រួសារ?

ខ៖ ចាមិនបានដេកមួយយប់ទេ មកមួយភ្លែតចឹងក៏ទៅវិញទៅ
មកតែមួយភ្លែតៗនឹងអត់ដែរបានយូរទេ

ក៖ ចុះផពុកម្តាយរបស់អ៊ុំសុំទៅលេងអ៊ុំដែរបានអត់អ៊ុំ?

ខ៖ ទៅតាយកបាយទៅ យកម្ហូបអីយកទៅអោយដែរ សុំបានតាលោកគ្រូ

ក៖ ប៉ុន្តែយើងទៅស្នាក់នៅកន្លែងគេតែម្តងហោសអ៊ុំ?

ខ៖ ចានឹងហើយ

ក៖ យើងអត់អាចមកផ្ទះវិលវិញពេទ្យល្ងាចវិញបានទេ?

ខ៖ នឹងហើយមិនបានទេ ដូចថាម៉ែគាត់នឹកចឹងគាត់ធ្វើម្ហូបរលីង
ពេលដែរឆ្អិនចឹងក៏យកទៅអោយចឹងទៅណាស់

ក៖ អូបាទអោយកូនៗផ្សេងៗទៀតទៅ?

ខ៖ យើងនៅជាមួយគ្នាក៏ចែកគ្នាហូបចឹងទៅ

ក៖ បាទអ៊ុំចុះឪពុកម្តាយរបស់អ៊ុំគាត់មានធ្លាប់ប្រាប់ថាកាលពីគាត់នៅក្មេងទៅប្រាប់អ៊ុំទេ
ថានៅក្មេងគាត់ធ្វើអីគេហើយនៅពេលមុនគាត់មិនបានគ្នាចឹងគាត់ធ្វើអីគេចេងហាស
ទាំងឪពុកទាំងម្តាយ?

ខ៖ ទេខ្ញុំមិនដែរបានសួរទេ ខ្ញុំធំដឹងក្ដីគេបានបញ្ជូនទៅកងចល័ត

ក៖ ប៉ុន្តែកាលពីអ៊ុំកើតមក
រឺមួយក៏អ៊ុំនៅក្មេងៗហាសតើគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងអីទេអ៊ុំអត់?

ខ៖ គាត់ធ្លាប់នៅតែភ្នំពេញនឹងគាត់មក គាត់រត់ស៊ីក្លូកាលពីគាត់នៅកំលោះអីចឹងហាស

ក៖ នឹងឪពុករបស់អ៊ុំកាលពីគាត់នៅកំលោះ?

ខ. គាត់ជាអ្នករត់ស៊ីក្លូ
ដល់ចាស់ពេលដែរបានយាយទៅក៏គាត់នៅតែរត់ចឹងដែរទាល់តែបែកជំនាន់ពលពតចឹង
ហាស

ក៖
ចុះម្ដាយរបស់អ៊ុំគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងៗដូចជាយាយអីចឹងហាស
គាត់មានធ្លាប់ប្រាប់អីទេអ៊ុំទេ ហើយគាត់ធ្វើអីគេមុននឹងបានតា?

ខ៖ គាត់អត់មានបាននិយាយផងនឹង

ក៖ អូគាត់អត់ដែរបាននិយាយប្រាប់អ៊ុំតែម្ដងហោសអ៊ុំ?

ខ៖ ចាអត់ដែរបាននិយាយទេ

ក៖ ចុះអ៊ុំមានចងចាំយាយតានៅខាងម្ដាយរបស់អ៊ុំអត់
យាយតាខាងម្ដាយគាត់មានឈ្មោះអីអ៊ុំចងចាំអត់ទេអ៊ុំ?

ខ៖ ចាំតាលោកគ្រូ

ក៖ ពួកគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖ ឈ្មោះតា ងិន

ក៖ ឈ្មោះ តាងិន ចុះយាយមានឈ្មោះអីគេដែរអ៊ុំ?

ខ៖ យាយឈ្មោះយាយ ហៀក

ក៖ ឈ្មោះយាយហៀកណាអ៊ុំ ចុះយាយតាខាងម្ដាយអ៊ុំមានដឹងថាគាត់កើតនៅឆ្នាំណាអត់អ៊ុំ?

ខ៖ អត់ដឹងទេលោកគ្រូ

ក៖ ចុះគាត់ស្លាប់នៅឆ្នាំណាអ៊ុំមានចងចាំទេ?

ខ៖ អូមិនដឹងទេខ្ញុំកើតមិនទាន់ទេ

ក៖ អ៊ុំអត់មានចងចាំទេ ដោយសារតែវាយូដែរហើយណាអ៊ុំ?

ខ៖ ចាយូដែរហើយ

ក៖ ចុះយាយតាគាត់កើតនៅណាអ៊ុំមានអត់មានដឹងទេអ៊ុំ?

ខ៖ គាត់កើតនៅភូមិចំបក ឃុំគ្រួស ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង

ក៖ គាត់កើតនៅចំបកដែរទាំងយាយ ទាំងតា?

ខ៖ នឹងហើយគាត់កើតនៅចំបកនឹងនៅភូមិនឹងទាំងអស់គ្នានឹង

ក៖ ចុះយាយតាខាងឪពុកអ៊ុំមានចងចាំឈ្មោះពួកគាត់ទេអ៊ុំ?

ខ៖ ចាំតាលោកគ្រូ

ក៖ គាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖ គាត់ឈ្មោះ តាភឿក យាយហែម

ក៖ ឈ្មោះតាភឿក យាយហែម ចុះគាត់កើតនៅឆ្នាំណាអ៊ុំមានដឹងទេ?

ខ៖ អូយអត់ដឹងទេលោកគ្រូអើយគាត់បានស្លាប់យូរដែរហើយ
ហើយខ្ញុំសុទ្ធតែខ្ញុំមិនទាន់កើត

ក៖ ប៉ុន្តែពួកគាត់កើតនៅណាអីអ៊ុំដឹងហើយណា?

ខ៖ នៅចំបកនឹងដែរនឹង

ក៖ និយាយរួមយាយតាម្តាយរបស់បង
នឹងយាយតាខាងឪពុកគាត់កើតនៅណុងទាំងងស់នឹង?

ខ៖ គាត់កើតនៅណុងអែង គាត់កើតនៅភូមិចំបកទាំងអស់គ្នានឹង

កៈ ដូចជាអ៊ុំមកលេងកូនទេណបង?

ខៈ ខ្ញុំមកមើលចៅ

កៈ អូអ៊ុំមកមើលចៅណអ៊ុំ ប្រហែលជាប៉ុន្មានខែដែរអ៊ុំទៅវិញទៅ?

ខៈ ប្រហែលជា2-3ខែអីនឹងទៅវិញហើយ

កៈ អូចុះប៉ុន្តែកូនចៅរបស់អ៊ុំគាត់នៅនឹងរហូត?

ខៈ នៅនឹងអែង

កៈ ប៉ុន្តែកូនចៅរបស់អ៊ុំគាត់មកនៅភ្នំពេញនឹងយូរនៅអ៊ុំ?

ខៈ គេនៅយូរដែរហើយ គេមករកស៊ីនៅនឹង

កៈ ប្រហែលជាប៉ុន្មានឆ្នាំដែរទៅអ៊ុំ?

ខៈ ប្រហែលជាចូល5-6ឆ្នាំហើយ

កៈ ប៉ុន្តែសំរាប់អ៊ុំនៅស្វាយរៀង នៅស្វាយជ្រុំនឹងដូចជាអ៊ុំនៅខេត្តនៅយូរនៅអ៊ុំ?

ខៈ នៅយូរដែរហើយលោកគ្រូ

កៈ នៅប្រហែលជាប៉ុន្មានឆ្នាំដែរហើយអ៊ុំ?

ខៈ ពីមុនគេដាក់ភូមិចំបក ឃុំគ្រួស ស្រុកស្វាយរៀង ខេត្តស្វាយរៀង
តែឥឡូវគេដាក់ស្រុកស្វាយជ្រុំវិញហើយ

កៈ ប៉ុន្តែអ៊ុំនៅនឹងយូរបានប៉ុន្មានដែរហើយ?

ខៈ ខ្ញុំនៅនឹងដាក់ស្វាយជ្រុំនឹង

កៈ អត់ទេអ៊ុំបានរស់នៅនឹងប៉ុន្មានឆ្នាំដើយអ៊ុំ?

ខៈ អូរស់នៅនឹងយូរដែរហើយលោកគ្រូ

កៈ តាំងពីអ៊ុំកើតមករឺមួយយ៉ាងម៉េចដែរអ៊ុំ?

ខៈ តាំងពីកើតមកនឹង

កៈ ពីមុននឹងកើតទៀត
ចឹងវាចូលប្រហែលជា50ឆ្នាំជាងហើយពីព្រោះតែអ៊ុំឥឡូវចូល55ឆ្នាំហើយមែនទេអ៊ុំ?

ខៈ នឹងហើយយូរដែរហើយ

កៈ អូចុះអ៊ុំមានមិត្តភក្តិណាដែររស់នៅក្រៅប្រទេស ក្រៅពីប្រទេសកម្ពុជាអត់អ៊ុំ?

ខៈ អត់មានទេលោកគ្រូអើយ

កៈ អត់មានទេណាអ៊ុំ ដូចជា នៅថៃ វៀតណាមអីអត់មានទេណាអ៊ុំ?

ខៈ អត់មានទេ

កៈ ចុះនៅព្រៃងអង្គរអីក៏អត់មានដែរ?

ខៈ អត់មានទេលោកគ្រូ

កៈ ប៉ុន្តែមានធ្លាប់ទៅរកស៊ីនៅណុាង ដូចជាកូនចៅអីនៅពីមុនហាស?

ខៈ មិនដែរទេ

កៈ ចុះស្វាមីរបស់អ៊ុំគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខៈ គាត់មានឈ្មោះ សូ ឌី

កៈ ឈ្មោះ សូ ឌីណាអ៊ុំ ប៉ុន្តែឥឡូវគាត់នៅស្រុកនឹងមែនអ៊ុំ?

ខៈ គាត់នៅប៉ោយប៉ែត

កៈ គាត់នៅប៉ោយប៉ែត ចុះដូចជាអ៊ុំបានរៀបការនៅឆ្នាំណា ថ្ងៃណា ខែអីចឹងហាសអ៊ុំ?

ខៈ អត់ចាំទេបើតាបានចាំ

កៈ ប៉ុន្តែអ៊ុំមានដឹងថាប្រហែលជាប៉ុន្មានឆ្នាំដែរអ៊ុំ?

ខៈ អត់ចាំទេ ខ្ញុំករនឹងឆ្នាំដែរបែកហើយនឹង

កៈ បែកហើយ ចុះកូនរបស់អ៊ុំកាត់អាយុប៉ុន្មានដែរហើយអ៊ុំ?

ខៈ កូនរបស់ខ្ញុំទើបតែអាយុ21ឆ្នាំនឹង

កៈ អូប៉ុន្តែការហើយអ៊ុំ

ខៈ អត់ទាន់មានទេ

កៈ អូអត់ទាន់មានទេណាអ៊ុំ ប៉ុន្តែកាលពីអ៊ុំការនឹងអ៊ុំការនៅឆ្នាំ79ហីអ៊ុំ?

ខៈ ចា នៅឆ្នាំ1979

កៈ ការនៅឆ្នាំ1979ដល់ឥឡូវប្រហែលជា39ឆ្នាំ អ៊ុំបានការអស់រយះពេល39ឆ្នាំហើយអ៊ុំ?

ខៈ ចាប្រហែលជាប៉ុណ្ណឹង

កៈ ដូចជាអ៊ុំរៀបចំអាពាហ៍ពិពាហ៍នឹងដូចជាអ៊ុំជាអ្នករៀបចំដោយខ្លួនអែង រឺមួយក៏ឪពុកម្ដាយជាអ្នករៀបចំអោយដែរអ៊ុំ រឺក៏បងប្អូនដែរ?

ខៈ ទេទាំងអស់គ្នាលោកគ្រូ មិនមេនតែចិត្តអែងទេ

កៈ ដូចជាអ៊ុំត្រូវហើយអ៊ុំប្រាប់ពួកគាត់រឺមួយយ៉ាងម៉េចដែរអ៊ុំ?

ខៈ ចាត្រូវគ្នា

កៈ ចុះកាលពីប្ដីរបស់អ៊ុំបានចូលស្ដីដណ្ដឹងអ៊ុំនឹងដូចជាមានជាចំនួយអីទេអ៊ុំទេ?

ខៈ កាលណុងមិនទាន់មានអីទេ

កៈ កាលណុងអត់មានទាន់មានអីទេណាអ៊ុំចេញលុយរៀងខ្លួនហោសអ៊ុំ?

ខៈ ចេញរៀងខ្លួនការ

កៈ ប៉ុន្តែខាងប្រុកគេដូចជាចេញជាគោ រឺមួយជាម្ហូបអីអោយណាអ៊ុំ?

ខៈ ចេញជាម្ហូបអីចឹងទៅ

កៈ ចុះអ៊ុំអាចប្រាប់ខ្ញុំបានទេថាអ៊ុំជួបជាមួយតា ហើយបានជួបនៅពេលណាដែរ ហេតុអីបានជាអ៊ុំបានស្រលាញ់គ្នាអីចឹងហាសអ៊ុំ?

ខៈ នៅផ្ទះជិតគ្នាតាលោកគ្រូ

កៈ អូដូចជាយើងមើលគ្នាប៉ុន្មានខែហើយបានយើងចាប់អារម្មណ៍គ្នាចឹងហាសអ៊ុំ អ៊ុំអាចប្រាប់បន្តិចបានទេអ៊ុំ?

ខ៖ ចុះមានទៅថី ម៉ែឪត្រូវចិត្តក៏អោយចឹងទៅ ហើយត្រូវទាំងអស់គ្នាចឹងទៅណាស់

ក៖ ប៉ុន្តែខាងគេមើលយើងប៉ុន្មានខែហើយបានគេចូលមកយើងដែរអ៊ុំ?

ខ៖ ម៉ែឪខាងគេចូលដណ្តឹងអោយចឹងទៅ

ក៖ អូប៉ុន្តែយើងមានបានទាក់ទងគ្នាហើយនៅអ៊ុំ?

ខ៖ អត់មានទាក់ទងអីទេ

ក៖ អូចឹងម៉ែឪគេទាំងសងខាងគេឃើញក៏គេចាប់អារមណ៍ទៅ?

ខ៖ ចានឹងហើយ

ក៖ ចុះអ៊ុំមានចេះភាសាខ្មែរ រឺមួយក៏ចេះអាន រឺក៏សរសេរអក្សរបានល្អប៉ុណ្ណាដែរអ៊ុំ?

ខ៖ ខ្ញុំចេះសរសេរតិចៗដែរនឹង

ក៖ អ៊ុំចូលរៀននៅថ្នាក់ទីប៉ុន្មានដែរអ៊ុំ?

ខ៖ ខ្ញុំរៀននៅជំនាន់ពលពតបានច្រើនដែរ ខ្ញុំរៀងការពីជំនាន់ពីដើមនឹងបានថ្នាក់ទី11នឹង

ក៖ អូអ៊ុំបានរៀនដល់ថ្នាក់ទី11ហោស?

ខ៖ ថ្នាក់ទី11គេពីមុនស្មើនឹងថ្នាក់ទី2ឥឡូវនឹង

ក៖ អូបាទ
ចុះកាលពីអ៊ុំរៀននៅសាលាបឋមសិក្សានឹងសាលារបស់អ៊ុំមានឈ្មោះអីគេដែរអ៊ុំ?

ខ៖ សាលាពោធំ

ក៖ សាលាឈ្មោះពោធំណាអ៊ុំ ចុះសាលានឹងនៅណាវិញអ៊ុំ?

ខ៖ សាលាខាងកើតនៅខាងឃុំគ្រួស

ក៖ នៅភូមិចំបក នឹងហោសអ៊ុំ?

ខ៖ នៅឃុំចំបក ភូមិគ្រួស

ក៖ ប៉ុន្តែនៅភូមិគ្រួស ចុះអ៊ុំមានចេះភាសាអីក្រៅពីភាសាខ្មែរអត់អ៊ុំ?

ខ៖ ខ្ញុំអត់ចេះទេលោកគ្រូ

ក៖ ចុះវៀតណាមអីក៏អត់ចេះដែរហោសអ៊ុំ?

ខ៖ អត់ចេះទេ

ក៖ ចុះភាសាបារាំងអីអ៊ុំចេះទេ?

ខ៖ បារាំងអីក៏មិនចេះដែរ

ក៖ ចុះអ៊ុំមានមិត្តភក្តិណាដែរធំមកជាមួយគ្នា
ប៉ុន្តែនៅតែស្និទ្ធិស្នាលដែរធំមកជាមួយគ្នាហាសអ៊ុំមានអត់អ៊ុំ?

ខ៖ មានម្នាក់

ក៖ ចុះគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖ ឈ្មោះ មាស ដួន

ក. ឈ្មោះ មាស ដួន តែគាត់នៅរស់សព្វថ្ងៃនឹងទេណាអ៊ុំ?

ខ៖ នៅរស់តា នៅផ្ទះហោស

ក៖ ប៉ុន្តែគាត់នៅជិតផ្ទះអ៊ុំដែរណាអ៊ុំ?

ខ៖ នៅជិតណុង

ក៖ ចុះអ៊ុំមានចងចាំអនុស្សាវរីយ៍អីជាមួយអ៊ុំមាស ដួននឹងទេអ៊ុំ?

ខ៖ គ្មានប្រវត្តិអីទេលោកគ្រូ

ក៖ ដូចជាយើងទៅរៀនជាមួយគ្នាហើយយើងទៅដើរលេងអីជាមួយគ្នាអីចឹងហាស?

ខ៖ អូដើរលេងទៅមើល

ក៖ ទៅមើលគោ ទៅមើលអីចឹងទៅ?

ខ៖ មើលល្ខោន មើលកុន មើលអីជាមួយគ្នាចឹងទៅ

ក៖ អូកាលពីជំនាន់ណុងមានកុនដែរហោសអ៊ុំ មានតែល្ខោនតាហី?

ខ៖ មានកុន មានល្ខោនអីនឹងមានទើបតែបែកហើយណុង

ក៖ ប៉ុន្តែឥឡូវនឹងនៅតែដើរទៅមើលកុនអីជាមួយគ្នាទៅ?

ខ៖ ឥឡូវនឹងមិនដែរទេពីព្រោះតែចាស់ហើយនឹង

ក៖ ប៉ុន្តែទៅវត្តអីជាមួយគ្នាដែរតាហីអ៊ុំ?

ខ៖ ទៅៗវត្តតា

ក៖ ទៅវត្តទៅសំសិល្បិ៍អីជាមួយគ្នាចឹងទៅ ចុះអ៊ុំធ្លាប់ទៅធ្វើការនៅវាលស្រែអត់អ៊ុំ?

ខ៖ ធ្វើការនៅស្រែចឹមិនមានលោកគ្រូ

ក៖ ទៅដកស្ទូងអីទៅ?

ខ៖ ទៅដកស្ទូង ទៅបោចស្មៅ រែកជីរែកអីនឹង

ក៖ បាទអ៊ុំចុះអ៊ុំមានធ្លាប់បើអាជីវកម្មលក់ដូរអីមួយក៏ចិញ្ចឹមមាន់ ទា ជ្រូក គោអីទេអ៊ុំ?

ខ៖ មានចិញ្ចឹមជ្រូក តែដល់ពេលដែរខ្ញុំនៅម្នាក់អែងខ្ញុំក៏ឈប់ចិញ្ចឹមទៅ នៅតែគោម្នាក់អែងហាត់ណាស់លោកគ្រូ

ក៖ អូបាទអ៊ុំ ធ្លាប់មានការលក់ដូរអីអត់អ៊ុំ?

ខ៖ ខ្ញុំធ្លាប់លក់ម្តងតែពេលខ្ញុំលក់តែម្នាក់អែងហាត់ពេកក៏ឈប់លក់វិញទៅ

ក៖ ហាត់ហោសអ៊ុំ ប៉ុន្តែចំណេញច្រើនហោសអ៊ុំ?

ខ៖ ចំណេញអី មួយមុខចំណេញ400-500រឺមួយក៏ចំណេញ200-300អីនឹងមិនច្រើនទេចាប់ហួយ

ក៖ ចុះអ៊ុំធ្លាប់ធ្វើការអីគេខ្លះនៅក្នុងជីវិតរបស់អ៊ុំដែរ?

ខ៖ ជីវិតរបស់ខ្ញុំមានតែការដកស្ទូងតែមួយនឹង ចាប់ហួយតិចតួចនឹង

ក. លក់ចាប់ហួយនឹងការដកស្ទូង ធ្វើស្រែចំការដែល?

ខ៖ ធ្វើស្រែចំការ ដកស្ទូង ចិញ្ចឹមទា ចិញ្ចឹមគោ ចិញ្ចឹមជ្រូកអី តែឥឡូវនឹងខ្ញុំចិញ្ចឹមនៅសល់តែគោ

កៈ ប៉ុន្តែអ៊ុំចិញ្ចឹមគោនឹងចិញ្ចឹមច្រើនអត់អ៊ុំ?

ខៈ មិនមានច្រើនទេ

កៈ លក្ខណៈថាមាន4-5ក្បាលអីចឹងហោសអ៊ុំ?

ខៈ ខ្ញុំលក់អស់ហើយ ចាខ្ញុំលក់

កៈ អ៊ុំមិនមែនចិញ្ចឹមជាលក្ខណៈកសិដ្ឋានណាហីអ៊ុំ?

ខៈ មិនមែនទេមិនមែនជាកសិដ្ឋានទេ ចិញ្ចឹមនៅក្នុងលក្ខណៈជាគ្រួសារ

កៈ អូចិញ្ចឹមលក្ខណៈថាជាគ្រួសារ ចិញ្ចឹមលក្ខណៈថា4-10ក្បាលអីចឹងទៅ?

ខៈ នៅចិញ្ចឹម4-5ក្បាល ប៉ុន្តែខ្ញុំលក់អស់ហើយ នៅតែម៉ែកូន2ក្បាលនឹងអ៊ុំ

កៈ អូនៅម៉ែកូន2ក្បាលហោសអ៊ុំ?

ខៈ ខ្ញុំលក់អស់ហើយគ្មានមនុស្សមើល នឹងមកនឹងផ្ញើរគេនឹងហាស

កៈ អូម៉ែកូនគោ2ក្បាលនឹងនៅផ្ញើរគេ

ខៈ ផ្ទះចាក់សោរចោល

កៈ ហាកចឹងអត់មាននរណាគេនៅជាមួយទេហអ៊ុំ?

ខៈ គ្មានផងនឹង

កៈ ដល់ពេលដែរតាទៅវិញបានតានៅជាមួយ?

ខៈ ចានឹងហើយ

កៈ ចុះប៉ុន្តែកូននឹងចៅៗអីអត់មាននរណាគេនៅជាមួយទេ?

ខៈ ចៅរបស់ខ្ញុំមានតែ2នាក់នឹង ហើយកូនមានតែ2នាក់ដែរនឹង
ម្នាក់ធ្វើការនៅកាណាឌីយ៉ានឹង

កៈ អូចឹងមានន័យថាកូនរបស់អ៊ុំមកនៅភ្នំពេញទាំងអស់
ចុះប៉ុន្តែបងប្អូនរបស់អ៊ុំអត់មាននរណាគេនៅមើលអីទេ?

ខ៖ មានទាំងអស់នឹងបានជាខ្ញុំផ្ញើរគេនឹង

ក៖ អូបាទអ៊ុំ
ចុះតាំងពីក្មេងរហូតមកដល់ពេលនេះអ៊ុំកិតថាជីវិតរបស់អ៊ុំមានការផ្លាស់ប្ដូរអីគេខ្លះដែរហោសអ៊ុំ កាលពីនៅក្មេងយ៉ាងម៉េច ហើយឥឡូវយ៉ាងម៉េចដែរចឹងហាស?

ខ៖ ការផ្លាស់ប្ដូរវាផ្លាស់ហើយលោកគ្រូ
កាលពីក្មេងវានៅក្មេងតែដល់ពេលឥឡូវវាចាស់ទៅរាងចាស់នឹងហាសលោកគ្រូ

ក៖ ប៉ុន្តែឥឡូវនឹងសុខភាពនឹងយ៉ាងម៉េចដែរអ៊ុំ?

ខ៖ សុខភាពនឹងមិនសូវជាល្អទេលោកគ្រូ
មើលនេះងេសងោសៗនឹងផ្ដាស់សាយតែរហូតនឹង

ក៖ ប៉ុន្តែឥឡូវសុខភាពចុះខ្សោយដែរអត់អ៊ុំ?

ខ៖ នឹងហើយចុះខ្សោយដែរនឹង

ក៖ ហាសមកដល់ទីណាមកជួបអ៊ុំរហូតនឹង

ខ៖ នេះមកលេងប្អូននឹង

ក៖ អ៊ុំគឺជាប្អូនរបស់អ៊ុំហោស?

ខ៖ ចាជាជីដូនមួយនឹង

ក៖ ចុះអ៊ុំចូលចិត្តពិសារម្ហូបអីគេដែរអ៊ុំ?

ខ៖ ខ្ញុំចូលចិត្តតែក្រៀមៗមិនសូវនេះទេ

ក៖ អាំង ស្ងោរ ចុះសម្លម្ជូរគ្រឿង នឹងម្ជូរយួនអីអ៊ុំចូលចិត្តទេ?

ខ៖ ម្ជូរគ្រឿងនឹងឧស្សាហ៍ដែរនឹង

ក៖ ចុះការី រឺកកូរអីនឹង?

ខ៖ ការីខ្ញុំមិនចូលចិត្តទេខ្ញុំមកនៅភ្នំពេញខ្ញុំណាយអាការី គ្រឿងនោះនឹង អាស្លកកូរគ្រឿង

ក៖ គ្រឿងកកូរហើអ៊ុំ?

ខ៖ នឹងហើយខ្ញុំណាយ

ក៖ ចុះមានល្បែងប្រជាប្រិយ៍អីគេដែរអ៊ុំចូលចិត្តលេងជាងគេតាំងពីក្មេងហាស ដូចជាចោលឈូង បោះអង្គុញ ទាញព្រាត អីចឹងហាសអ៊ុំ?

ខ៖ ចូលចិត្តដូចតែគ្នានឹង តាមាននឹងអោយតែមាននឹងចូលចិត្តទាំងអស់នឹង

ក៖ អូអ៊ុំចូលចិត្តដូចគ្នាហោស ចុះអ៊ុំចេះច្រៀងទេអ៊ុំ?

ខ៖ ចេះច្រៀងតាលោកគ្រូ

ក៖ បទចំរៀងអីដែរអ៊ុំគិតថាអ៊ុំចូលចិត្តច្រៀងហោសអ៊ុំ?

ខ៖ ខ្ញុំចូលចិត្តទាំងអស់នឹងទាំងជំនាន់ដើម នឹងជំនាន់សម័យឥឡូវនឹងចឹង

ក៖ ប៉ុន្តែគិតថាបទអីដែរអ៊ុំគិតថានៅតែចូលចិត្តច្រៀងចឹងហាសបទអីគេដែរអ៊ុំ?

ខ៖ អូភ្លេចអស់ហើយលោកគ្រូ ពេលលោកគ្រូអែងសួរចឹងខ្ញុំភ្លេចអស់ហើយ

ក៖ រាំវង្ស លាំលាវអីចឹង ម៉ាឌីហ្សូនអីចឹងហាស?

ខ៖ លាំលាវក៏ចេះដែរ

ក៖ អូចុះអ៊ុំមាននរណានៅក្នុងក្រុមគ្រួសាររបស់អ៊ុំចេះលេងឧបករណ៍ភ្លេងអីអត់ទេអ៊ុំ?

ខ៖ គ្មានទេលកោគ្រូ

ក៖ បងប្អូនជីដូនមួយអីក៏អត់មានដែរហោសអ៊ុំ?

ខ៖ ចាអត់មានទេ តែមានតែខ្ញុំទេដែរជំនាញច្រៀងជាងគេ

ក៖ អត់អីទេចាំខ្ញុំទៅចាំច្រៀងទាំងអស់គ្នា កូរពេញនៅស្រុកស្វាយជ្រុំតែម្តង

ខ៖ ទេមិនបាច់ចាំទៅទេនៅកន្លែងលោកគ្រូអែងតែម្តងទៅ កីឡូវបានដាក់សំលេងខ្លះ

ក៖ ចុះផ្ទះរបស់អ៊ុំមានលក្ខណះបែបណាតាំងពីក្មេងរហូតមកដល់ពេលនេះហាស ថាផ្ទះកាលពីក្មេងនឹងយ៉ាងម៉េចចឹងហាស?

ខ៖ ពីក្មេងខ្ញុំមិនចូលចិត្តទេកាលពីជំនាន់ពលពតខ្ញុំខាងសិល្ប៍

កៈ ប៉ុន្តែផ្ទះរបស់អ៊ុំហាស?

ខៈ ផ្ទះរបស់ខ្ញុំពីដើមនឹងសុទ្ធផ្ទះប្រស្លឹកនឹង សួរផ្ទះពីដើមអី?

កៈ បាទផ្ទះរបស់អ៊ុំពីដើមហាស?

ខៈ គេធ្វើដូចកត់អីនោះ

កៈ តែផ្ទះឥឡូវផ្ទះឈើមែនទេអ៊ុំ?

ខៈ ផ្ទះឈើប្រកសំណ

កៈ អូផ្ទះឈើ
ប្រកសំណចុះនរណាគេជាអ្នកសាងសងផ្ទះមួយនឹងដូចជាជួលគេរឺមួយសាងសងដោយខ្លួនអែងដែរ?

ខៈ ជួលគេតាលោកគ្រូ

កៈ ជួលគេធ្វើទៅរួចហើយអោយលុយគេទៅ?

ខៈ ចាជួលគេនឹង

កៈ ចុះមានជំនាញអីដែរអ៊ុំគិតថាអ៊ុំចេះស្ទាត់ជំនាញហាសដូចជាធ្វើកន្ទេលធ្វើអីចឹងហាស?

ខៈ ធ្វើកន្ទេលុំអញ្ចូត

កៈ អូចេះធ្វើកន្ទេលអញ្ចូតដែរណាអ៊ុំ?

ខៈ ចាចេះធ្វើកន្ទេលរំចេក

កៈ អ៊ុំចេះមួយនឹងហោស ចុះអ៊ុំចេះក្ងរស្កត្នោត រឺមួយក៏វេញវល្លិ៍អីអត់អ៊ុំ?

ខៈ វេញត្នោតម៉េចទៅ?

កៈ អត់ទេវេញវល្លិ៍អីចឹងហាស?

ខៈ អូធ្វើខ្សែកន្លុកមិនចេះទេ ប៉ុន្តែបើការពិតបើធ្វើបណ្តុះអាសន្នបាន

កៈ ប៉ុន្តែអ៊ុំចេះធ្វើផ្តៅអត់?

ខ៖ ផ្តៅគ្មាននៅស្រុកខ្ញុំនោះ

ក៖
ចុះអ៊ុំអាចប្រាប់ខ្ញុំបានទេថាតើពេលណាដែរអ៊ុំគិតថាជាពេលដែរអ៊ុំលំបាកជាងគេចឹងហាស អ៊ុំ?

ខ៖ ទេបើជីវិតដូចឥឡូវគ្មានលំបាកអីទេលោកគ្រូ ធម្មតា

ក៖ តែកាលពីនៅក្មេងវិញ?

ខ៖ ពិបាកតែកាលពីជំនាន់ពលពតតិចនឹង

ក៖ គេបានអោយយើងភៀសខ្លួនអោយយើងចេញពីឪពុកម្តាយចឹងទៅ?

ខ៖ គ្មានស្អីទេ មកសម័យឥឡូវគ្មានអីទេ សប្បាយឥឡូវកាន់តែសប្បាយទៀតណ

ក៖ ហាសឥឡូវកាន់តែសប្បាយ

ខ៖ កាលពីជំនាន់ពលពតវាបំបែកយើង ដូចថាម៉ែដោយម៉ែ ចឹងទៅកូនដោយកូនចឹងទៅ

ក៖ ចុះអ៊ុំឆ្លងកាត់វាដោយរបៀបណាដែរអ៊ុំ
ដូចជាអ៊ុំឆ្លងកាត់ការលំបាកនឹងដោយរបៀបណាដែរអ៊ុំ?

ខ៖ អើម ពិបាកមែនទែននឹងហាសលោកគ្រូ

ក៖ ប៉ុន្តែឆ្លងកាត់របៀបយ៉ាងណាដែរទៅ ហើយជំនះវាដោយរបៀបណាទៅ?

ខ៖ ជំនះម៉េចលោកគ្រូ

ក៖ លក្ខណះថាព្យាយាមវាទៅ ចង់និយាយថាពេលដែរអ៊ុំជួបការលំបាកនឹង
តើអ៊ុំធ្វើម៉េចដើម្បីអោយឈ្នះការលំបាកនឹងបានដែរ?

ខ៖ មិនដឹងឆ្លងកាត់ម្នាក់អែងនឹងម៉េចទេលោកគ្រូ ទៅទាំងអស់គ្នាថា

ក៖
ចុះអ៊ុំគិតថាពេលណាដែរអ៊ុំគិតថាជាពេលដែរសប្បាយជាងគេនៅក្នុងជីវិតរបស់អ៊ុំដែរហាស អ៊ុំ?

ខ៖ ហាសសម័យឡូវនឹងសប្បាយហាសណាលោកគ្រូ

ក៖ ប៉ុន្តែ ដូចជាជួបជុំមិត្តភក្តិរឺមួយជាប់ការកូនចៅ?

ខ៖ អូសប្បាយណាស់នៅតែផ្ទះរាល់តែថ្ងៃនឹងក៏សប្បាយដែរនឹង
ជួបជុំគ្នាចូលគ្នាស្រាបៀកន្លះកេះ ទិញសាច់ក្លែម

ក៖ ប៉ុន្តែពេលដែរជួបជុំមិត្តភក្តិដែរធ្វើអោយអ៊ុំសប្បាយណាអ៊ុំ?

ខ៖ ចានឹងហើយជាការសប្បាយណាស់

ក៖ ចុះអ៊ុំអាចប្រាប់ខ្ញុំបានថាអ៊ុំធ្លាប់មានក្តីស្រម៉ៃ
រឺមួយក៏ក្តីសង្ឃឹមថាធំឡើងអ៊ុំចង់ធ្វើអីគេដែរទេអ៊ុំ ដូចជាធ្វើគ្រូបង្រៀន រឺធ្វើគ្រូពេទ្យ
រឺជាអ្នកជំនួញលក់អីមួយចឹងហាស?

ខ៖ អានឹងអត់មានសង្ឃឹមទេ ខ្ញុំសង្ឃឹមតែច្រៀងរាំ

ក៖ ច្រៀងរាំប៉ុន្តែកាលពីអ៊ុំនៅតូចអ៊ុំមានធ្លាប់មានក្តីស្រម៉ៃអីគេកាលពីអ៊ុំនៅរៀនហាស
គិតថាពេលដែរអ៊ុំធំឡើងអ៊ុំចង់ធ្វើពេទ្យ រឺមួយក៏ធ្វើគ្រូអីអត់អ៊ុំ?

ខ៖ មានអីមានអីទេពីព្រោះតែយើងធ្វើមិនបានកាលពីជំនាន់ពលពត យើងអត់សង្ឃឹម
ដល់ពេលដែរបែកឆ្នាំ1979នឹងការតែម្តងនឹង
អត់បានរៀនទៀតចឹងហាសដល់ពេលនឹងយើងអត់មានគោលបំណងចង់ប៉ងអីទេ

ក៖ អូបាទអ៊ុំអត់មានក្តីអីទេ?

ខ៖ ចានឹងហើយ

ក៖ ចុះបើចង់អោយអ៊ុំផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗតើអ៊ុំចង់ផ្តែផ្តាំអីគេទៅពួកគាត់ដែរអ៊ុំ
ដូចជាចៅអីៗ រឺកូនយ៉ាងម៉េចចឹងហាស?

ខ៖ ចង់អោយធ្វើពេទ្យបានលុយ

ក៖ ចង់ធ្វើពេទ្យហោស នេះជាក្តីបំណងរបស់អ៊ុំ?

ខ៖ ចាក្តីបំណងរបស់ខ្ញុំ ចង់អោយធ្វើពេទ្យពីព្រោះពេទ្យគេមិនចេះតថ្លៃទេ

ក៖ អូចឹងចង់អោយគាត់ខំប្រឹងរៀនកុំអោយគាត់ដើរលេង

ខ៖ ចានឹងហើយចឹង

ក៖ ចុះមានអីផ្សេងទៀតទេអ៊ុំ?

ខ៖ មានតែប៉ុណ្ណឹងលោកគ្រូ

ក៖ បាទចឹងជាចុងក្រោយអ៊ុំដែរបានអោយខ្ញុំបានសំភាសន៍ពីប្រវត្តិរបស់អ៊ុំ ហើយនឹងផ្តល់ពេលវេលាដែរបានអោយខ្ញុំបានពិភាក្សាជាមួយអ៊ុំចឹងហាសអ៊ុំ បាទចឹងខ្ញុំអរគុណច្រើនអ៊ុំ៕៕៕